ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ២២១
ថ្ងៃ: ពុធ ទី២៤ ខែវិច្ឆិកា ២០២១
ម៉ោង: ១៤ : ៥៥ នាទី

# ព្រះរាជក្រម

នស/រកម/១១២១/០១៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្តមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្ដីពី
# ភាពជាដៃគូរវាងរដ្ឋនិងឯកជន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងលើកកម្ពស់ការគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន សរសេរជាអក្សរកាត់ថា ភ.រ.ជ. ក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ចីរភាព តម្លាភាព គណនេយ្យភាព និងយុត្តិធម៌ ដើម្បីជាឧត្តមប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម នៅព្រះរាជាណាចក្រកម្ពុជា ដោយៈ

- កំណត់ស្ថាប័នមានសមត្ថកិច្ចសម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោងភ.រ.ជ. ជាលក្ខណៈប្រព័ន្ធ
- បង្កើតក្របខ័ណ្ឌដើម្បីអភិវឌ្ឍ អនុវត្ត គ្រប់គ្រង និងតាមដានត្រួតពិនិត្យគម្រោងភ.រ.ជ.
- បង្កើតវិធាន វិធីសាស្ត្រ នីតិវិធី និងរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងនិងអនុវត្តកិច្ចលទ្ធកម្ម ក្នុងក្របខ័ណ្ឌគម្រោងភ.រ.ជ.
- កំណត់យន្តការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការលើកទឹកចិត្តវិនិយោគសម្រាប់គម្រោងភ.រ.ជ.។

**មាត្រា២ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងលើការអភិវឌ្ឍនិងការអនុវត្តគម្រោងភ.រ.ជ. ក្នុងវិស័យមានលក្ខណសម្បត្តិគ្រប់គ្រាន់ស្របតាមមាត្រា៨នៃច្បាប់នេះ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិង/ឬផ្តល់សេវាសាធារណៈ។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់នៅក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធ១នៃច្បាប់នេះ។

# ជំពូកទី២
# ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាស្ថាប័នមានសមត្ថកិច្ចក្នុងការដឹកនាំនិងគ្រប់គ្រងយន្តការ ភ.រ.ជ. នៅព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទីនិងភារកិច្ចជាអាទិ៍ៈ

- ជាសេនាធិការនិងជា"ច្រកចេញចូលតែមួយ"របស់រាជរដ្ឋាភិបាល ក្នុងការទទួលបន្ទុកគម្រោងភ.រ.ជ. ក្នុងគ្រប់ដំណាក់កាលនៃវដ្តគម្រោង។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២- ស្នើឡើងនូវគោលនយោបាយអភិវឌ្ឍន៍យន្តការភ.រ.ជ. និងដឹកនាំការរៀបចំបទប្បញ្ញត្តិ នីតិវិធីគ្រប់គ្រងប្រតិបត្តិការនិងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការរៀបចំអភិវឌ្ឍនិងគ្រប់គ្រងគម្រោង ភ.រ.ជ. ជាមួយស្ថាប័នសាមី។

៣- រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យរបស់គម្រោងភ.រ.ជ.ដែលមាន សង្គតិភាពជាមួយក្របខ័ណ្ឌរួមសម្រាប់គ្រប់គ្រងយន្តការភ.រ.ជ.។

៤- ពិនិត្យនិងអនុម័តសំណើគម្រោងដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ អនុវត្តតាមយន្តការ ភ.រ.ជ. ដោយផ្អែកលើលក្ខណវិនិច្ឆ័យពាក់ព័ន្ធ។

៥- ពិនិត្យលើការបែងចែកការទទួលបន្ទុកហានិភ័យនៃគម្រោងភ.រ.ជ. រវាងរដ្ឋនិងដៃគូ ឯកជន ដើម្បីធានាអនុលោមភាពជាមួយនឹងច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រ កម្ពុជា និងដើម្បីធានាចីរភាពហិរញ្ញវត្ថុសាធារណៈ។

៦- ពិនិត្យនិងផ្តល់យោបល់លើកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងការគាំទ្រពីរដ្ឋសម្រាប់ គម្រោងភ.រ.ជ.។

៧- ពិនិត្យនិងផ្តល់យោបល់លើកិច្ចសន្យាភ.រ.ជ. និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការអនុវត្ត គម្រោងភ.រ.ជ.។

៨- សហការជាមួយស្ថាប័នសាមីនិងស្ថាប័នពាក់ព័ន្ធដើម្បីពិនិត្យនិងតាមដានកាតព្វកិច្ច និងសមិទ្ធកម្មនៃការអនុវត្តគម្រោង ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

៩- ពិនិត្យនិងអនុម័តលើសំណើរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ស្ថាប័នសាមីពាក់ព័ន្ធនឹង កាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈនិងការគាំទ្រពីរដ្ឋដែលរាជរដ្ឋាភិបាលបានសន្យាបំពេញក្រោម ក្របខ័ណ្ឌគម្រោងភ.រ.ជ.។

១០- រៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីបច្ចុប្បន្នភាពនៃកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈដែល រាជរដ្ឋាភិបាលបានសន្យាបំពេញក្នុងកិច្ចសន្យាភ.រ.ជ.។

១១- រៀបចំថវិកា គ្រប់គ្រង និងប្រតិបត្តិការ សម្រាប់មូលនិធិអភិវឌ្ឍន៍គម្រោង។

១២- រៀបចំថវិកា គ្រប់គ្រង និងប្រតិបត្តិការ សម្រាប់មូលនិធិបំពេញផលហិរញ្ញវត្ថុ។

**មាត្រា៥ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវមានអគ្គនាយកដ្ឋានមួយជាសេនាធិការក្នុងការដឹកនាំនិង គ្រប់គ្រងយន្តការភ.រ.ជ. នៅព្រះរាជាណាចក្រកម្ពុជា។ ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋាននេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ស្ថាប័នសាមីជាស្ថាប័នមានសមត្ថកិច្ចក្នុងការអភិវឌ្ឍគម្រោងនិង/ឬការបំពេញតួនាទីជា ភាគីចុះកិច្ចសន្យាភ.រ.ជ. ជាមួយនឹងដៃគូឯកជន ដែលមានតួនាទីនិងភារកិច្ចជាអាទិ៍ៈ

១- ធ្វើអត្តសញ្ញាណកម្មនិងអាទិភាវូបនីយកម្មគម្រោងនៅក្នុងវិស័យឬដែនសមត្ថកិច្ចរបស់ខ្លួន និងរៀបចំសំណើសុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យជ្រើសរើសនិងសម្រេចកំណត់សំណើគម្រោងនោះ ជាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចបានកំណត់នៅក្នុងមាត្រា៨នៃច្បាប់នេះ។

២- ជ្រើសរើសនិងគ្រប់គ្រងទីប្រឹក្សាគាំទ្រដល់ការរៀបចំអភិវឌ្ឍនិងការអនុវត្តគម្រោងភ.រ.ជ.។

៣- អនុវត្តឬត្រួតពិនិត្យលើការអនុវត្តការសិក្សាសមិទ្ធិលទ្ធភាពបឋមនិងពេញលេញ រួចពិនិត្យនិងផ្តល់ការឯកភាពទៅលើរបាយការណ៍លទ្ធផលនៃការសិក្សានោះ។

៤- លើកសំណើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យលើលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាព មុននឹងបន្តនីតិវិធីជាធរមាន។

៥- ដឹកនាំក្រុមការងាររបស់រាជរដ្ឋាភិបាលអនុវត្តកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជន ដែលនឹងត្រូវអនុវត្តកិច្ចសន្យាភ.រ.ជ.។

៦- ដឹកនាំក្រុមការងាររបស់រាជរដ្ឋាភិបាលចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. និងចុះហត្ថលេខាលើកិច្ចសន្យាភ.រ.ជ. ក្នុងនាមជាតំណាងរបស់រាជរដ្ឋាភិបាល។

៧- គ្រប់គ្រងនិងអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងកិច្ចសន្យាភ.រ.ជ.។

៨- លើកសំណើរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈនិងការគាំទ្រពីរដ្ឋដែលរាជរដ្ឋាភិបាលបានសន្យាបំពេញ ក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ.។

៩- តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តនិងប្រតិបត្តិការគម្រោងភ.រ.ជ. ទាំងមូល។

ស្ថាប័នសាមីត្រូវអនុវត្តតួនាទីនិងភារកិច្ចដូចមានចែងក្នុងកថាខណ្ឌ១ខាងលើ ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

១- ត្រូវអនុវត្តសិទ្ធិនិងបំពេញភារកិច្ច ក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ. ប្រកបដោយសុចរិតភាពនិងដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមខនិងលក្ខខណ្ឌនៃកិច្ចសន្យាភ.រ.ជ.។

២- ត្រូវទទួលខុសត្រូវដោយផ្ទាល់លើការស្នើសុំថវិកាសម្រាប់ចំណាយលើការរៀបចំការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យគម្រោងភ.រ.ជ.។

## ជំពូកទី៣

## សិទ្ធិចុះកិច្ចសន្យានិងលក្ខណសម្បត្តិគ្រប់គ្រាន់នៃគម្រោង ភ.រ.ជ.

មាត្រា[illegible].-

ស្ថាប័នសាធារណៈដែលមានសិទ្ធិចុះកិច្ចសន្យាភ.រ.ជ.ក្នុងនាមជាស្ថាប័នសាមី រួមមាន [illegible] ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាស

សាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ស្ថាប័នសាធារណៈទាំងនេះមានសិទ្ធិចុះកិច្ចសន្យាភ.រ.ជ. ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បុគ្គលដែលមានសិទ្ធិទទួលការជ្រើសរើសនិងចុះកិច្ចសន្យាភ.រ.ជ.ក្នុងនាមជាដៃគូឯកជន ដោយអនុលោមតាមជំពូកទី៦នៃច្បាប់នេះត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្រុមហ៊ុនដែលបានចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២- ក្រុមហ៊ុនពាណិជ្ជកម្មបរទេសដែលបានចុះបញ្ជីស្របតាមច្បាប់បរទេស។

៣- សហគ្រាសសាធារណៈដែលមិនមែនជាស្ថាប័នសាមី និងដែលទទួលបានប្រតិភូកម្មអំណាច ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

បុគ្គលដូចមានចែងក្នុងចំណុច២ ក្នុងកថាខណ្ឌ២ខាងលើ ដែលបានចុះកិច្ចសន្យាភ.រ.ជ. និងដែលមិនមានកាតព្វកិច្ចបង្កើតក្រុមហ៊ុនមានគោលបំណងពិសេសដូចមានចែងក្នុងមាត្រា២២ នៃច្បាប់នេះ ត្រូវមកចុះបញ្ជីស្របតាមច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨ .-**

វិស័យមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលពាក់ព័ន្ធនឹងការសាងសង់និង/ឬការផ្គត់ផ្គង់សេវាសម្រាប់គម្រោងភ.រ.ជ.រួមមាន៖

- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈបម្រើដល់វិស័យដឹកជញ្ជូននិងវិស័យភស្តុភារកម្ម មានជាអាទិ៍ផ្លូវថ្នល់ ស្ពាន ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ ចំណតសាធារណៈ និងព្រែកជីក
- ហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល
- ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី បំពង់បង្ហូរប្រេងនិងឧស្ម័ន និងសេវាសាធារណៈផ្សេងទៀត ក្នុងវិស័យរ៉ែនិងថាមពល
- ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក ប្រព័ន្ធបូមស្តារ ប្រព្រឹត្តិកម្មទឹកកខ្វក់ ការគ្រប់គ្រងសំណល់ និងសេវាសាធារណៈផ្សេងទៀតបម្រើឱ្យកិច្ចគាំពារបរិស្ថាន
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យទេសចរណ៍ វិស័យវប្បធម៌និងសិល្បៈ វិស័យកីឡា និងលំនៅឋានសង្គម
- ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានជាអាទិ៍តំបន់សេដ្ឋកិច្ចពិសេស សួនបណ្តុះឧស្សាហកម្មធុនតូចនិងមធ្យម និងសួនបច្ចេកវិទ្យានិងនវានុវត្តន៍
- ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងសេវាមន្ទីរពិសោធន៍ ការគាំទ្រការកែច្នៃ ការរក្សាផលិតផល និងការជំរុញពាណិជ្ជកម្ម
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យកសិកម្មនិងប្រព័ន្ធធារាសាស្ត្រ
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈផ្សេងទៀតដែលច្បាប់ដោយឡែកអនុញ្ញាត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៩ .–**

ការធ្វើអត្តសញ្ញាណកម្មនិងការជ្រើសរើសគម្រោងភ.រ.ជ. ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ត្រូវបំពេញតាមលក្ខណវិនិច្ឆ័យទាំងអស់ដូចខាងក្រោម៖

១- ការរៀបចំនិងអនុវត្តគម្រោងនោះ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវនិងក្នុងដែនសមត្ថកិច្ចរបស់ស្ថាប័នសាមី។

២- គម្រោងនោះត្រូវមានគោលដៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិង/ឬការផ្តល់សេវាសាធារណៈ នៅក្នុងវិស័យដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។

៣- គម្រោងនោះត្រូវមានលទ្ធភាពបែងចែកការទទួលបន្ទុកហានិភ័យនៃគម្រោងរវាងរដ្ឋនិងដៃគូឯកជន ដើម្បីឱ្យមានផលចំណេញតាមគោលការណ៍តម្លៃនៃលុយ។

៤- គម្រោងនោះត្រូវមានសក្តានុពលក្នុងការទាក់ទាញធនធានពីវិស័យឯកជន ដើម្បីឱ្យមានមូលដ្ឋានក្នុងការធ្វើវិចារណកម្មចំណាយធនធានសាធារណៈសម្រាប់ការរៀបចំអភិវឌ្ឍគម្រោង។

៥- គម្រោងនោះត្រូវមានរយៈពេលប្រតិបត្តិការយ៉ាងតិច៥(ប្រាំ)ឆ្នាំ និងអាចផ្តល់សេវាកម្មដល់អ្នកប្រើប្រាស់ប្រកបដោយស្ថិរភាពនិងចីរភាព ក្នុងអាយុកាលទាំងស្រុងនៃគម្រោងក្រោមក្របខ័ណ្ឌកិច្ចសន្យាភ.រ.ជ.។

គោលការណ៍ណែនាំនៃការធ្វើអត្តសញ្ញាណកម្មនិងការជ្រើសរើសគម្រោងភ.រ.ជ. ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

## ជំពូកទី៤
## វដ្តនៃគម្រោងភ.រ.ជ.

**មាត្រា១០ .–**

វដ្តនៃគម្រោងភ.រ.ជ.ផ្តួចផ្តើមដោយរដ្ឋ ត្រូវបានកំណត់ដូចខាងក្រោម៖

១- **ការធ្វើអត្តសញ្ញាណកម្មគម្រោង** : ស្ថាប័នសាមីត្រូវធ្វើអត្តសញ្ញាណកម្មគម្រោងដែលមានសក្តានុពលក្នុងការរៀបចំអភិវឌ្ឍនិងអនុវត្តតាមយន្តការភ.រ.ជ.។

២- **ការជ្រើសរើសគម្រោង** : ស្ថាប័នសាមីដែលមានបំណងរៀបចំអភិវឌ្ឍនិងអនុវត្តគម្រោងតាមយន្តការភ.រ.ជ. ត្រូវវាយតម្លៃសក្តានុភាពនិងអាទិភាពនៃគម្រោងនោះ មុននឹងរៀបចំសំណើសុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ ជ្រើសរើស និងសម្រេចកំណត់សំណើគម្រោង ជាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់និងដាក់បញ្ចូលសំណើគម្រោងនោះទៅក្នុងបញ្ជីគម្រោងអាទិភាពក្នុងក្របខ័ណ្ឌ

គម្រោង ភ.រ.ជ.។ ការវាយតម្លៃគម្រោងដោយស្ថាប័នសាមីនិងការជ្រើសរើសសំណើគម្រោងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្អែកទៅលើលក្ខណវិនិច្ឆ័យ ដូចមានចែងក្នុងមាត្រា៩នៃច្បាប់នេះ។

៣- **ការរៀបចំអភិវឌ្ឍគម្រោង** : ស្ថាប័នសាមីដែលមានសមត្ថកិច្ចក្នុងវិស័យពាក់ព័ន្ធនឹងគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ ត្រូវចាត់ចែងឱ្យមានការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងនោះ។

៤- **ការអនុម័តគម្រោង** : ប្រសិនបើស្ថាប័នសាមីឯកភាពតាមលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោង ស្ថាប័នសាមីត្រូវលើកសំណើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យមុននឹងបន្តនីតិវិធីជាធរមាន។

៥- **កិច្ចលទ្ធកម្ម** : បន្ទាប់ពីការអនុម័តលើគម្រោង ស្ថាប័នសាមីត្រូវអនុវត្តកិច្ចលទ្ធកម្ម ដូចមានចែងក្នុងជំពូកទី៦នៃច្បាប់នេះ ដើម្បីជ្រើសរើសបេក្ខភាពដៃគូឯកជនក្នុងការអនុវត្តគម្រោងភ.រ.ជ.។

៦- **ការចរចាលើកិច្ចសន្យាភ.រ.ជ.** : បន្ទាប់ពីការជ្រើសរើសបេក្ខភាពដៃគូឯកជនរួចហើយ ស្ថាប័នសាមីត្រូវដឹកនាំក្រុមការងាររបស់រាជរដ្ឋាភិបាល ក្នុងការចរចាលើខនិងលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ.។

៧- **ការអនុម័តលើសេចក្តីព្រាងចុងក្រោយនៃកិច្ចសន្យាភ.រ.ជ.** : បន្ទាប់ពីការចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ត្រូវបានបញ្ចប់ ស្ថាប័នសាមីត្រូវស្នើសុំការសម្រេចអនុម័តពីរាជរដ្ឋាភិបាលលើសេចក្តីព្រាងចុងក្រោយនៃកិច្ចសន្យាភ.រ.ជ. បន្ទាប់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាពជាគោលការណ៍ដូចមានចែងក្នុងចំណុច២ កថាខណ្ឌ១ ក្នុងមាត្រា២១នៃច្បាប់នេះ។

៨- **ការចុះហត្ថលេខាលើកិច្ចសន្យាភ.រ.ជ.** : ស្ថាប័នសាមីដែលទទួលបានប្រតិភូកម្មអំណាចស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងនាមជាភាគីរដ្ឋនិងដៃគូឯកជនត្រូវចុះហត្ថលេខាលើកិច្ចសន្យាភ.រ.ជ. ដោយមានការចុះហត្ថលេខារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៩- **ការអនុវត្តនិងគ្រប់គ្រងកិច្ចសន្យាភ.រ.ជ.** :

ក- ដៃគូឯកជនត្រូវទទួលខុសត្រូវជាចម្បង ចំពោះការរៀបចំហិរញ្ញប្បទាន ការរចនាប្លង់វិស្វកម្មលម្អិតការអនុវត្តកិច្ចលទ្ធកម្មជ្រើសរើសអ្នកម៉ៅការ ការងារសាងសង់ ការងារប្រតិបត្តិការ និង/ឬការងារថែទាំ ដោយស្របតាមខនិងលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ. និងអនុលោមតាមបទប្បញ្ញត្តិក្នុងជំពូកទី៩នៃច្បាប់នេះ។

ខ- ស្ថាប័នសាមីត្រូវគ្រប់គ្រង តាមដាន និងរៀបចំរបាយការណ៍អំពីការអនុវត្តកិច្ចសន្យាភ.រ.ជ. ដែលខ្លួនបានចុះហត្ថលេខា ដោយអនុលោមតាមមាត្រា៤០នៃច្បាប់នេះ។

នីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភ.រ.ជ. ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

**មាត្រា ១២.-**

ស្ថាប័នសាមីអាចប្រើប្រាស់សេវាទីប្រឹក្សាដើម្បីគាំទ្រការងាររៀបចំអភិវឌ្ឍនិង/ឬវាយតម្លៃគម្រោងកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជននិងការងារពាក់ព័ន្ធផ្សេងទៀត។ ការទូទាត់ថ្លៃសេវាកម្មរបស់

ទីប្រឹក្សាអាចប្រើប្រាស់ថវិកាថ្នាក់ជាតិ ថវិកាថ្នាក់ក្រោមជាតិ ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ថវិកាសហគ្រាសសាធារណៈ មូលនិធិអភិវឌ្ឍន៍គម្រោង ជំនួយផ្សេងៗរបស់ដៃគូអភិវឌ្ឍនិង/ឬប្រភពថវិកាស្របច្បាប់ផ្សេងទៀត។

នីតិវិធីនៃការជ្រើសរើសទីប្រឹក្សា ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

# ជំពូកទី៥
# យន្តការគាំទ្រផ្នែកហិរញ្ញវត្ថុ

**មាត្រា១២ .-**

ត្រូវបានបង្កើតមូលនិធិអភិវឌ្ឍន៍គម្រោង ដើម្បីផ្តល់ថវិកាដល់ស្ថាប័នសាមីសម្រាប់ចំណាយលើទីប្រឹក្សាដែលគាំទ្រការងាររៀបចំអភិវឌ្ឍនិង/ឬវាយតម្លៃគម្រោង អនុវត្តកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជននិងការងារពាក់ព័ន្ធផ្សេងទៀត។

គោលការណ៍ណែនាំនៃការគ្រប់គ្រងប្រតិបត្តិការមូលនិធិអភិវឌ្ឍន៍គម្រោង ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

**មាត្រា១៣ .-**

ការផ្តល់ការគាំទ្រពីរដ្ឋសម្រាប់គម្រោងភ.ឯ.ជ. អាចមានទម្រង់ដូចខាងក្រោម៖

១- **ការបំពេញផលហិរញ្ញវត្ថុ** : ជាការឧបត្ថម្ភធនពីរដ្ឋជូនចំពោះដៃគូឯកជន ដើម្បីបន្ថយចំណាយមូលធនរបស់ដៃគូឯកជននិងបង្កើនផលចំណេញផ្នែកហិរញ្ញវត្ថុរបស់គម្រោង។ ការទូទាត់ប្រាក់ឧបត្ថម្ភធនបែបនេះ ត្រូវអនុវត្តតាមការសម្រេចបង្គោលចរសមិទ្ធផលការងារ នៅក្រោយពេលការងារសាងសង់បានចាប់ផ្តើមនិងអាចបន្តយូរបំផុតត្រឹម២(ពីរ)ឆ្នាំ ក្រោយពេលការងារសាងសង់បានបញ្ចប់ជាស្ថាពរ។ គោលការណ៍លម្អិតនៃការបំពេញផលហិរញ្ញវត្ថុត្រូវអនុវត្តតាមនីតិវិធីនៃការគ្រប់គ្រងមូលនិធិបំពេញផលហិរញ្ញវត្ថុ។

២- **ការទូទាត់ថ្លៃសេវាផ្អែកលើថវិការដ្ឋ** : ជាការទូទាត់ទាំងស្រុងឬមួយចំណែកនៃថ្លៃសេវារបស់ដៃគូឯកជនសម្រាប់ការងារធ្វើប្រតិបត្តិការលើទ្រព្យសម្បត្តិគម្រោងភ.ឯ.ជ.និង/ឬការផ្តល់សេវាកម្មដល់អ្នកប្រើប្រាស់សាធារណៈ។ ការទូទាត់ថ្លៃសេវាផ្អែកលើថវិការដ្ឋអាចអនុវត្តបានក្នុងករណីរាជរដ្ឋាភិបាលឯកភាពថាកម្រៃសេវាដែលដៃគូឯកជនត្រូវប្រមូលពីអ្នកប្រើប្រាស់សាធារណៈ មិនគ្រប់គ្រាន់ ឬមិនអាចប្រមូលបាន ឬមិនគួរប្រមូលពីអ្នកប្រើប្រាស់សាធារណៈ។ ការទូទាត់បែបនេះត្រូវធ្វើតែនៅក្រោយពេលការងារសាងសង់ត្រូវបានបញ្ចប់ជាស្ថាពរក្នុងករណីមានការសាងសង់ និងនៅពេលប្រតិបត្តិការការងារគម្រោងត្រូវបានចាប់ផ្តើម។

៣- **កាតព្វកិច្ចបំណុលជាយថាហេតុរបស់រដ្ឋ** : ជាកិច្ចធានាមួយចំនួនដែលផ្តល់ជូនដៃគូឯកជនឬភាគីពាក់ព័ន្ធក្នុងករណីពិសេសដើម្បីដោះស្រាយផលប៉ះពាល់ដែលអាចនឹងកើតឡើងដោយសារ

ព្រឹត្តិការណ៍ជាយថាហេតុនិង/ឬហានិភ័យដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ការសម្រេចផ្តល់កិច្ចធានាត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ អាស្រ័យលើលក្ខណៈនៃគម្រោងភ.រ.ជ.នីមួយៗ រាជរដ្ឋាភិបាលអាចផ្តល់កិច្ចធានាដែលមានទម្រង់ដូចខាងក្រោម៖

ក- **កិច្ចធានាសមិទ្ធកម្មតាមកិច្ចសន្យា** : ជាកិច្ចធានាដែលផ្តល់សំណងក្នុងករណីស្ថាប័នសាមីឬស្ថាប័នសាធារណៈណាមួយមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ. ឬកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការអនុវត្តគម្រោងភ.រ.ជ.។

ខ- **កិច្ចធានាចំពោះហានិភ័យអធិបតេយ្យឬនយោបាយ** : ជាកិច្ចធានាដែលផ្តល់សំណងក្នុងករណីសកម្មភាពនយោបាយឬគោលនយោបាយរបស់រាជរដ្ឋាភិបាល ធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានចំពោះដៃគូឯកជន មានជាអាទិ៍ករណីអស្សាមិករណ៍ ករណីជាតូបនីយកម្ម និងករណីអំពើហិង្សាដែលកើតឡើងដោយសារសកម្មភាពនយោបាយ។

គ- **កិច្ចធានាផ្សេងទៀត** : ជាកិច្ចធានាទម្រង់ផ្សេងទៀតដែលអនុម័តដោយរាជរដ្ឋាភិបាល អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៤- **វិភាគទានជាទ្រព្យសម្បត្តិ** : ជាការផ្តល់វិភាគទានដែលជាទ្រព្យសម្បត្តិរដ្ឋចំពោះគម្រោងភ.រ.ជ.។

៥- **ការលើកទឹកចិត្តវិនិយោគ** : ជាការផ្តល់ការលើកទឹកចិត្តវិនិយោគនិង/ឬការរៀបចំគោលនយោបាយអនុគ្រោះចំពោះការវិនិយោគ ដោយអនុលោមតាមជំពូកទី៨នៃច្បាប់នេះ។

**មាត្រា១៤ .-**

ការគាំទ្រពីរដ្ឋសម្រាប់គម្រោងភ.រ.ជ.ដែលមានលក្ខណៈជាថវិកាអាចមានប្រភពហិរញ្ញប្បទានដូចខាងក្រោម៖

១- ថវិកាថ្នាក់ជាតិ ថវិកាថ្នាក់ក្រោមជាតិ ថវិការបស់អង្គភាពសាធារណៈប្រហាក់ប្រហែលថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនិង/ឬថវិការបស់សហគ្រាសសាធារណៈ។

២- ជំនួយអភិវឌ្ឍន៍ផ្លូវការ ដូចជាប្រាក់កម្ចីឬជំនួយឥតសំណង ដែលរាជរដ្ឋាភិបាលទទួលបានពីដៃគូអភិវឌ្ឍ។

៣- មូលនិធិបំពេញផលហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា១៥នៃច្បាប់នេះ។

**មាត្រា១៥ .-**

ត្រូវបានបង្កើតមូលនិធិបំពេញផលហិរញ្ញវត្ថុដែលជាប្រភពហិរញ្ញប្បទានពិសេសមួយសម្រាប់ការបំពេញផលហិរញ្ញវត្ថុដល់គម្រោងភ.រ.ជ.។

នីតិវិធីនៃការគ្រប់គ្រងមូលនិធិបំពេញផលហិរញ្ញវត្ថុ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

**មាត្រា១៦ .-**

គម្រោងភ.រ.ជ.ណាដែលទទួលបានការគាំទ្រពីរដ្ឋជាថវិកាឬត្រូវផ្ទេរប្រាក់ជូនរដ្ឋត្រូវធ្វើប្រតិបត្តិការទាំងនេះ តាមរយៈគណនីនៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ កិច្ចសន្យាភ.រ.ជ.អាចតម្រូវឱ្យមានគណនីនៅធនាគារបន្ថែមទៀត តាមតម្រូវការចាំបាច់។

# ជំពូកទី៦
# ការជ្រើសរើសដៃគូឯកជន

**មាត្រា១៧ .-**

ការជ្រើសរើសដៃគូឯកជនអាចធ្វើឡើងសម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋនិងសម្រាប់គម្រោងផ្តួចផ្តើមដោយឯកជន។

**មាត្រា១៨ .-**

ការជ្រើសរើសដៃគូឯកជនសម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋអាចអនុវត្តតាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងឬតាមវិធីសាស្ត្រការចុះកិច្ចសន្យាផ្ទាល់។

នីតិវិធីនៃការជ្រើសរើសដៃគូឯកជនសម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

**មាត្រា១៩ .-**

ដំណើរការនៃការចរចាលើកិច្ចសន្យាភ.រ.ជ.សម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋដែលអនុវត្តតាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែង ត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកដេញថ្លៃជាប់លំដាប់លេខរៀងទី១ ត្រូវបានអញ្ជើញមកចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ជាមួយក្រុមការងាររបស់រាជរដ្ឋាភិបាលដែលដឹកនាំដោយស្ថាប័នសាមី ដូចមានចែងក្នុងចំណុច៦នៃកថាខណ្ឌ១ ក្នុងមាត្រា១០នៃច្បាប់នេះ។ ក្នុងករណីដែលអ្នកដេញថ្លៃជាប់លំដាប់លេខរៀងទី១នោះខកខានក្នុងការចូលរួមការចរចាតាមការអញ្ជើញ ស្ថាប័នសាមីអាចអញ្ជើញអ្នកដេញថ្លៃជាប់លំដាប់លេខរៀងបន្ទាប់ មកចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ.។

២- ក្នុងករណីដែលការចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ដូចមានចែងក្នុងចំណុច១នៃកថាខណ្ឌ១ខាងលើ មិនបានបញ្ចប់ក្នុងរយៈពេល៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញឱ្យចូលចរចាដំបូង នោះស្ថាប័នសាមីអាចអញ្ជើញអ្នកដេញថ្លៃជាប់លំដាប់លេខរៀងបន្ទាប់ មកចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ.។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣- ឯកសារប្រកាសការអញ្ជើញដាក់សំណើសុំចូលរួមដេញថ្លៃអាចបញ្ជាក់ជាមុននូវខ និងលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ដែលមិនអាចចរចាបាន។

គោលការណ៍លម្អិតសម្រាប់ការចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. តាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងសម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋ ត្រូវកំណត់ក្នុងនីតិវិធីនៃការជ្រើសរើសដៃគូឯកជន។

**មាត្រា២០ .-**

ស្ថាប័នសាមីអាចអនុវត្តវិធីសាស្ត្រការចុះកិច្ចសន្យាផ្ទាល់សម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋ ក្នុងករណីមានការសម្រេចពីរាជរដ្ឋាភិបាល តាមសំណើរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នសាមី។

គោលការណ៍លម្អិតសម្រាប់ការចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. តាមវិធីសាស្ត្រការចុះកិច្ចសន្យាផ្ទាល់ ត្រូវកំណត់នៅក្នុងនីតិវិធីនៃការជ្រើសរើសដៃគូឯកជន។

**មាត្រា២១ .-**

ដំណើរការនៃការបញ្ចប់ការរៀបចំនិងចុះហត្ថលេខាលើកិច្ចសន្យាភ.រ.ជ.សម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋ ត្រូវបានកំណត់ដូចខាងក្រោម៖

១- បន្ទាប់ពីការចរចាលើខនិងលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ត្រូវបានបញ្ចប់ ស្ថាប័នសាមីត្រូវរៀបចំសំណើសុំការអនុម័តលើសេចក្តីព្រាងចុងក្រោយនៃកិច្ចសន្យាភ.រ.ជ. ដូចមានចែងក្នុងចំណុច៧ នៃកថាខណ្ឌ១ ក្នុងមាត្រា១០នៃច្បាប់នេះ។

២- មុននឹងស្នើសុំការអនុម័តដូចមានចែងក្នុងចំណុច១ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវពិនិត្យឡើងវិញលើខនិងលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ដែលពាក់ព័ន្ធនឹងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈនិងការគាំទ្រពីរដ្ឋ រួចបន្តនីតិវិធីតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ខនិងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងការគាំទ្រពីរដ្ឋក្នុងកិច្ចសន្យាភ.រ.ជ.មានជាអាទិ៍៖

ក- ប្រភេទហានិភ័យនិងការបែងចែកការទទួលបន្ទុកហានិភ័យរវាងភាគីរដ្ឋនិងដៃគូឯកជន។

ខ- ការគាំទ្រពីរដ្ឋដូចមានចែងក្នុងមាត្រា១៣នៃច្បាប់នេះ។

គ- កាតព្វកិច្ចរបស់រដ្ឋដូចមានចែងក្នុងមាត្រា៣៤នៃច្បាប់នេះ។

៣- បន្ទាប់ពីការអនុម័តលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ.ដូចមានចែងក្នុងចំណុច១និង២ នៃកថាខណ្ឌ១ខាងលើ កិច្ចសន្យានោះត្រូវមានការចុះហត្ថលេខាដោយស្ថាប័នសាមីនិងដៃគូឯកជន និងការចុះហត្ថលេខារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គោលការណ៍លម្អិតនៃការបញ្ចប់ការរៀបចំនិងអនុម័តលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ផ. ត្រូវកំណត់នៅក្នុងនីតិវិធីនៃការជ្រើសរើសដៃគូឯកជន។

**មាត្រា២២ .-**

ក្រុមហ៊ុនមានគោលបំណងពិសេសអាចត្រូវបង្កើតឡើង ដើម្បីធ្វើជាដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ផ. តាមតម្រូវការជាក់ស្តែងរបស់គម្រោងនីមួយៗ។

ការបង្កើតក្រុមហ៊ុនមានគោលបំណងពិសេស ដើម្បីធ្វើជាដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ផ. ត្រូវអនុលោមតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ក្រុមហ៊ុនមានគោលបំណងពិសេសត្រូវបង្កើតឡើងជាសហគ្រាសពាណិជ្ជកម្ម ដោយចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២- ការបង្កើតនិងការចុះបញ្ជីក្រុមហ៊ុនមានគោលបំណងពិសេសត្រូវបញ្ចប់យ៉ាងយូរបំផុតត្រឹម៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាភ.រ.ផ.។

៣- ក្នុងរយៈពេល១៤(ដប់បួន)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការបង្កើត និងការចុះបញ្ជីក្រុមហ៊ុនមានគោលបំណងពិសេស ភាគីនៃកិច្ចសន្យាភ.រ.ផ.និងក្រុមហ៊ុនមានគោលបំណងពិសេសត្រូវចុះកិច្ចព្រមព្រៀងនវកម្ម ដើម្បីធ្វើអនុប្បទានឋានៈរបស់ដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ផ. ជូនក្រុមហ៊ុនមានគោលបំណងពិសេស ដោយរក្សាខនិងលក្ខខណ្ឌនៃកិច្ចសន្យា ភ.រ.ផ. ដដែល។

**មាត្រា២៣ .-**

ស្ថាប័នសាមីអាចទទួលសំណើគម្រោងផ្តួចផ្តើមដោយឯកជន ដើម្បីពិនិត្យលទ្ធភាពរៀបចំអភិវឌ្ឍ និងអនុវត្តជាគម្រោងភ.រ.ផ.។ ការពិនិត្យនិងសម្រេចលើសំណើគម្រោងផ្តួចផ្តើមដោយឯកជនត្រូវអនុលោមតាមគោលការណ៍និងលក្ខខណ្ឌដូចខាងក្រោម៖

១- សំណើគម្រោងផ្តួចផ្តើមដោយឯកជនត្រូវមានទស្សនាទានថ្មី បច្ចេកវិទ្យាថ្មី ឬនវានុវត្តន៍ដែលអាចមានប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីស្ថាប័នសាមីមានបំណងបន្តការរៀបចំអភិវឌ្ឍសំណើគម្រោងផ្តួចផ្តើមដោយឯកជនណាមួយ ស្ថាប័នសាមីត្រូវរៀបចំសំណើសុំការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- បន្ទាប់ពីទទួលបានការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល ស្ថាប័នសាមីត្រូវដឹកនាំក្រុមការងាររបស់រាជរដ្ឋាភិបាលរៀបចំកិច្ចព្រមព្រៀងក្របខ័ណ្ឌ ឬកិច្ចព្រមព្រៀងណាមួយ ដើម្បីកំណត់ពីកិច្ចសហប្រតិបត្តិការរវាងភាគីរដ្ឋនិងម្ចាស់សំណើគម្រោងផ្តួចផ្តើមដោយឯកជន ក្នុងការសិក្សានិងអភិវឌ្ឍគម្រោង។ រាល់ចំណាយនិងហានិភ័យពាក់ព័ន្ធនឹងការសិក្សានិងអភិវឌ្ឍគម្រោង គឺជាបន្ទុករបស់ម្ចាស់សំណើគម្រោងផ្តួចផ្តើមដោយឯកជន។

៣- ស្ថាប័នសាមីនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចាត់ចែងឱ្យមានភ្នាក់ងារឯករាជ្យ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញឬធ្វើការវាយតម្លៃលើលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពរបស់ម្ចាស់សំណើគម្រោងផ្តួចផ្តើមដោយឯកជន។

៤- ផ្អែកលើការវាយតម្លៃនៃការសិក្សាសមិទ្ធិលទ្ធភាព ស្ថាប័នសាមីនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចស្នើសុំរាជរដ្ឋាភិបាលជ្រើសរើសដៃគូឯកជន តាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែង ឬតាមវិធីសាស្ត្រការចុះកិច្ចសន្យាផ្ទាល់។

៥- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចសម្រេចប្រើប្រាស់ថវិកាពីមូលនិធិអភិវឌ្ឍន៍គម្រោងសម្រាប់ការវាយតម្លៃភាពត្រឹមត្រូវនៃការសិក្សាសមិទ្ធិលទ្ធភាពនេះ លើទិដ្ឋភាពពាណិជ្ជកម្ម និងហិរញ្ញវត្ថុសម្រាប់ការចរចាលើខនិងលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. និងសម្រាប់ការងារពាក់ព័ន្ធផ្សេងទៀត។

នីតិវិធីនៃការជ្រើសរើសដៃគូឯកជនសម្រាប់គម្រោងផ្តួចផ្តើមដោយឯកជន ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

## ជំពូកទី៧
## កិច្ចសន្យាភ.រ.ជ.

**មាត្រា២៤ .-**

គោលការណ៍កិច្ចសន្យាភ.រ.ជ. ត្រូវបានកំណត់ដូចខាងក្រោមៈ

១- កិច្ចសន្យាភ.រ.ជ. ត្រូវរៀបចំឡើងដោយផ្អែកទៅលើលក្ខណៈពិសេសនៃគម្រោង ដូចមានកំណត់នៅក្នុងលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាព ដែលនឹងត្រូវមានការឯកភាពរវាងរាជរដ្ឋាភិបាលនិងដៃគូឯកជន។

២- កិច្ចសន្យាភ.រ.ជ. ត្រូវតែជាកិច្ចព្រមព្រៀងបែបពាណិជ្ជកម្មរវាងស្ថាប័នសាមីនិងដៃគូឯកជន។ ស្ថាប័នសាមីត្រូវទទួលខុសត្រូវក្នុងការធានាថា ការចុះកិច្ចសន្យាភ.រ.ជ. ប្រព្រឹត្តទៅប្រកបដោយតម្លាភាពនិងភាពយុត្តិធម៌សម្រាប់គម្រោងភ.រ.ជ.ទាំងអស់ ទាំងគម្រោងផ្តួចផ្តើមដោយរដ្ឋ និងទាំងគម្រោងផ្តួចផ្តើមដោយឯកជន។

៣- កិច្ចសន្យាភ.រ.ជ. ត្រូវបែងចែកការទទួលបន្ទុកហានិភ័យពាក់ព័ន្ធនឹងគម្រោងភ.រ.ជ. រវាងរាជរដ្ឋាភិបាលនិងដៃគូឯកជន ដោយធ្វើឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពទទួលផលចំណេញតាមគោលការណ៍តម្លៃនៃលុយ ប៉ុន្តែនៅតែមានលទ្ធភាពរក្សាផលចំណេញពីពាណិជ្ជកម្មក្នុងកម្រិតសមរម្យឱ្យដៃគូឯកជន។

៤- ការកំណត់ផលប្រយោជន៍ដែលដៃគូឯកជនមានសិទ្ធិទទួលបានក្នុងកិច្ចសន្យាភ.រ.ជ. ផ្អែកទៅលើសមិទ្ធកម្មនៃការអនុវត្តគម្រោង។

**មាត្រា២៥ .-**

សេចក្តីព្រាងកិច្ចសន្យាភ.រ.ជ.នីមួយៗត្រូវមានទម្រង់ផ្អែកទៅលើប្រភេទគម្រោងភ.រ.ជ.ដែលសមស្របណាមួយ។ ការកំណត់ប្រភេទគម្រោងភ.រ.ជ.សមស្រប អាស្រ័យទៅលើលក្ខណៈពិសេសនិងតម្រូវការជាក់ស្តែងរបស់គម្រោងនីមួយៗនិងត្រូវមានការសម្រេចដោយស្ថាប័នសាមីជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកទៅលើលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាព។

ប្រភេទគម្រោងភ.រ.ជ.ដែលមានការប្រើប្រាស់ជាទូទៅក្នុងការរៀបចំសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ត្រូវបានកំណត់ជាអាទិ៍ ដូចក្នុងឧបសម្ព័ន្ធ២នៃច្បាប់នេះ។

**មាត្រា២៦ .-**

ថ្លៃប្រើប្រាស់និងកម្រៃសេវាទាំងឡាយដែលអាចប្រមូលបានក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ. ព្រមទាំងរូបមន្តកែប្រែត្រូវមានការកំណត់នៅក្នុងកិច្ចសន្យាភ.រ.ជ.។ ការកំណត់នេះ ត្រូវឈរលើគោលការណ៍ធានាអត្រាផលចំណេញក្នុងកម្រិតសមរម្យចំពោះដៃគូឯកជន ប៉ុន្តែនៅតែអាចធានាតម្លៃសមរម្យចំពោះអ្នកប្រើប្រាស់និងភាគីរដ្ឋ។

ដៃគូឯកជនមានសិទ្ធិប្រមូល និងទទួលចំណូលពីថ្លៃប្រើប្រាស់ និងកម្រៃសេវាផ្សេងៗ និងមានសិទ្ធិធ្វើការកែប្រែថ្លៃប្រើប្រាស់និងកម្រៃសេវាទាំងនោះតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.និង/ឬកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការអនុវត្តគម្រោងភ.រ.ជ.។

**មាត្រា២៧ .-**

កិច្ចសន្យាភ.រ.ជ.ត្រូវគ្រប់គ្រងដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ដៃគូឯកជនអាចជ្រើសរើសច្បាប់គ្រប់គ្រងលើកិច្ចព្រមព្រៀងបន្ទាប់បន្សំដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យាភ.រ.ជ. វៀរលែងតែមានស្ថាប័នសាធារណៈនៃព្រះរាជាណាចក្រកម្ពុជាជាភាគីនៅក្នុងកិច្ចព្រមព្រៀងនោះ។

**មាត្រា២៨ .-**

ការធ្វើអនុប្បទានសិទ្ធិនិងកាតព្វកិច្ចណាមួយរបស់ដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ជ.ទៅឱ្យតតិយជន ត្រូវមានការឯកភាពពីរាជរដ្ឋាភិបាលជាមុនសិន វៀរលែងតែករណីសិទ្ធិចូលអន្តរាគមន៍ ដូចមានចែងក្នុងមាត្រា២៩នៃច្បាប់នេះ។

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់លក្ខខណ្ឌ រាប់បញ្ចូលទាំងលក្ខខណ្ឌដែលអនុប្បទាយី និងអនុប្បទានិកត្រូវបំពេញដើម្បីទទួលការឯកភាពពីរាជរដ្ឋាភិបាលលើការធ្វើអនុប្បទានសិទ្ធិនិងកាតព្វកិច្ចណាមួយរបស់ដៃគូឯកជននៅក្នុងកិច្ចសន្យាភ.រ.ជ.។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា២៩ .–**

គូភាគីនៃកិច្ចសន្យាភ.រ.ជ. អាចព្រមព្រៀងគ្នាក្នុងការផ្តល់សិទ្ធិចូលអន្តរាគមន៍ជូនចំពោះអ្នកផ្តល់ប្រាក់កម្ចីសម្រាប់គម្រោងនិង/ឬជូនចំពោះរាជរដ្ឋាភិបាល។ អ្នកទទួលសិទ្ធិចូលអន្តរាគមន៍អាចទទួលនិងអនុវត្តបន្តនូវសិទ្ធិនិងកាតព្វកិច្ច ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ. ក្នុងគោលបំណងធានាចីរភាពនៃការបំពេញកាតព្វកិច្ចរបស់ដៃគូឯកជន ក្រោមក្របខ័ណ្ឌកិច្ចសន្យាភ.រ.ជ.និង/ឬកិច្ចព្រមព្រៀងប្រាក់កម្ចីដែលពាក់ព័ន្ធនឹងគម្រោង។

**មាត្រា៣០ .–**

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់លក្ខខណ្ឌកែប្រែកិច្ចសន្យា។ លក្ខខណ្ឌដែលអាចធ្វើការកែប្រែកិច្ចសន្យាភ.រ.ជ.ពាក់ព័ន្ធនឹងការងារសាងសង់និង/ឬសេវា មានជាអាទិ៍ការផ្លាស់ប្តូរច្បាប់ឬបទប្បញ្ញត្តិ ការផ្លាស់ប្តូរទំហំឬបទដ្ឋានយថាប្រភេទជាតុចេញនៃការងារសាងសង់ ការកែប្រែថ្លៃប្រើប្រាស់សេវា បម្រែបម្រួលតម្រូវការសេវា ប្រធានសក្តិ ឬលក្ខខណ្ឌផ្សេងទៀត ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

ស្ថាប័នសាមីត្រូវស្នើសុំការសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើករណីកែប្រែកិច្ចសន្យាភ.រ.ជ.ដោយអនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មុននឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការកែប្រែលើកិច្ចសន្យាភ.រ.ជ. ជាមួយដៃគូឯកជន។

ការកែប្រែកិច្ចសន្យាភ.រ.ជ. ត្រូវអនុវត្តតាមគោលការណ៍ណែនាំសម្រាប់គ្រប់គ្រងកិច្ចសន្យាដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

## ជំពូកទី៨
## ការលើកទឹកចិត្តវិនិយោគសម្រាប់គម្រោង ភ.រ.ជ.

**មាត្រា៣១ .–**

បុគ្គលទាំងឡាយណាដែលអនុវត្តគម្រោងភ.រ.ជ. ត្រូវស្ថិតនៅក្រោមនីតិរបបនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានាស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣២ .–**

ដៃគូឯកជនអាចដាក់ពាក្យស្នើសុំការលើកទឹកចិត្តវិនិយោគសម្រាប់គម្រោងភ.រ.ជ.ដោយអនុលោមតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានិងច្បាប់ពាក់ព័ន្ធជាធរមានផ្សេងទៀត។

**មាត្រា៣៣ .–**

ការបង្កើតសិទ្ធិប្រាតិភោគពាក់ព័ន្ធនឹងទ្រព្យសម្បត្តិគម្រោង ត្រូវអនុលោមតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ក្នុងរយៈពេលនៃកិច្ចសន្យាភ.រ.ជ. ដៃគូឯកជនអាចបង្កើតសិទ្ធិប្រាតិភោគលើទ្រព្យសម្បត្តិ លើសិទ្ធិឬលើអត្ថប្រយោជន៍របស់ខ្លួនដែលពាក់ព័ន្ធនឹងកិច្ចសន្យាភ.រ.ជ. រួមមាន៖

ក- ប្រាតិភោគលើចលនទ្រព្យឬអចលនទ្រព្យពាក់ព័ន្ធនឹងគម្រោងដែលជាកម្មសិទ្ធិរបស់ដៃគូឯកជន។

ខ- ប្រាតិភោគលើផលនៃទ្រព្យធានាឬគណនីត្រូវទាររបស់ដៃគូឯកជន ដែលបានមកពីការធ្វើប្រតិបត្តិការលើទ្រព្យសម្បត្តិគម្រោងឬការផ្តល់សេវាកម្មដល់អ្នកប្រើប្រាស់សេវា។

គ- ការដាក់បញ្ចាំនៃសិទ្ធិប្រត្យក្សលើដី ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២- វិនិយោគិនអាចបង្កើតសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ខ្លួនក្នុងក្រុមហ៊ុនមានគោលបំណងពិសេស។

៣- ការបង្កើត ការចុះបញ្ជី និងការធ្វើសុក្រឹតកម្មលើសិទ្ធិប្រាតិភោគ ដូចមានចែងក្នុងចំណុច១ និង២នៃកថាខណ្ឌ១ខាងលើ ត្រូវអនុលោមតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ. ហើយត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣៤ .-**

រាជរដ្ឋាភិបាលអាចបង្កើតកាតព្វកិច្ចនានាចំពោះដៃគូឯកជនឬបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹងគម្រោងភ.រ.ជ. រាប់បញ្ចូលទាំងអ្នកផ្តល់ប្រាក់កម្ចីក្នុងគោលបំណងធ្វើឱ្យគម្រោងនោះមានសមិទ្ធិលទ្ធភាពផ្នែកហិរញ្ញវត្ថុ មានលទ្ធភាពទទួលហិរញ្ញប្បទាន និងមានលទ្ធភាពអនុវត្តការងារសាងសង់ និងប្រតិបត្តិការឱ្យបានទាន់ពេលវេលា។ កាតព្វកិច្ចទាំងនោះមានជាអាទិ៍៖

១- កិច្ចធានារបស់រាជរដ្ឋាភិបាលចំពោះដៃគូឯកជន ដូចមានចែងក្នុងចំណុច៣នៃកថាខណ្ឌ១ ក្នុងមាត្រា១៣នៃច្បាប់នេះ។

២- ការចុះកិច្ចព្រមព្រៀងផ្ទាល់រវាងស្ថាប័នសាមីនិងអ្នកផ្តល់ប្រាក់កម្ចី ដើម្បីបញ្ជាក់ពីកាតព្វកិច្ចរបស់ស្ថាប័នសាមី ដែលមានចែងនៅក្នុងកិច្ចសន្យាភ.រ.ជ.។

៣- ការធានាឱ្យមានសេវាសាធារណៈ ដែលដៃគូឯកជនត្រូវការជាចាំបាច់ក្នុងការបំពេញលក្ខកិច្ចរបស់ខ្លួនក្រោមក្របខ័ណ្ឌកិច្ចសន្យាភ.រ.ជ.។

៤- កាតព្វកិច្ចផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

ការអនុម័តនិងការអនុវត្តកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលទាំងឡាយក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ. ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៣៥ .-**

កិច្ចលទ្ធកម្មដី ការដោះស្រាយផលប៉ះពាល់ និងការផ្តល់សិទ្ធិពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋសម្រាប់គម្រោងភ.រ.ជ. ជូនដៃគូឯកជន ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់សិទ្ធិប្រត្យក្សលើដី ការបែងចែកការទទួលបន្ទុកចំណាយកិច្ចលទ្ធកម្មដីនិងចំណាយលើសិទ្ធិប្រត្យក្សលើដី ព្រមទាំងចំណាយពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋសម្រាប់គម្រោងភ.រ.ជ.។

**មាត្រា៣៦ .-**

ដៃគូឯកជនមានសិទ្ធិទិញរូបិយបណ្ណនិងផ្ទេររូបិយបណ្ណទាំងនេះទៅបរទេស តាមរយៈប្រព័ន្ធធនាគារដែលជាអន្តរការីប្រតិស្រុតិ ដើម្បីទូទាត់លើប្រតិបត្តិការពាណិជ្ជកម្ម ប្រតិបត្តិការដើមទុន និងប្រតិបត្តិការផ្សេងទៀត ដែលពាក់ព័ន្ធនឹងការវិនិយោគលើគម្រោងភ.រ.ជ.មានជាអាទិ៍៖

១- ការទូទាត់លើការនាំចូលទំនិញនិងសេវាកម្មពីបរទេស។

២- ការបង់ប្រាក់ដើមនិងការប្រាក់សម្រាប់កម្ចីពីបរទេស។

៣- ការបង់ថ្លៃអាជ្ញាបណ្ណនិងកម្រៃគ្រប់គ្រងជូនអង្គភាពបរទេស។

៤- ការទូទាត់លើការជួលឧបករណ៍និងម៉ាស៊ីនពីបរទេស។

៥- ចំពោះតែវិនិយោគិនបរទេស ការផ្ទេរទៅបរទេសនូវដើមទុន ប្រាក់ចំណេញ ប្រាក់ចំណូលពីការជម្រះបញ្ជីនៃការវិនិយោគនិងប្រាក់ចំណូលស្របច្បាប់ផ្សេងទៀត។

សកម្មភាពប្តូររូបិយបណ្ណរបស់ដៃគូឯកជន ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី៩

# ការអនុវត្តនិងការតាមដានគម្រោង

**មាត្រា៣៧ .-**

ដៃគូឯកជនអាចអនុវត្តកិច្ចសន្យាភ.រ.ជ. ដោយផ្ទាល់ខ្លួនឬតាមរយៈអ្នកម៉ៅការ។

បេក្ខភាពដៃគូឯកជនត្រូវបញ្ជាក់អ្នកម៉ៅការគន្លឹះរបស់ខ្លួនឱ្យបានច្បាស់លាស់នៅក្នុងឯកសារសំណើគម្រោង នៅពេលចូលរួមក្នុងដំណើរការលទ្ធកម្មជ្រើសរើសដៃគូឯកជន។ និយមន័យនៃអ្នកម៉ៅការគន្លឹះ អាស្រ័យលើលក្ខណៈពិសេសនិងវិសាលភាពនៃគម្រោងភ.រ.ជ.នីមួយៗ និងត្រូវកំណត់ក្នុងឯកសារសម្រាប់អនុវត្តកិច្ចលទ្ធកម្ម។ ការផ្លាស់ប្តូរអ្នកម៉ៅការគន្លឹះមិនត្រូវបានអនុញ្ញាតទេ លើកលែងតែមានការឯកភាពពីស្ថាប័នសាមីនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

ដៃគូឯកជនមានសិទ្ធិពេញលេញក្នុងការជ្រើសរើសនិងផ្លាស់ប្តូរអ្នកម៉ៅការណាដែលមិនមែន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជាអ្នកម៉ៅការគន្លឹះ ដោយពុំចាំបាច់សុំការឯកភាពពីស្ថាប័នសាមីជាមុនឡើយ។

ទោះបីជាមានឬមិនមានអ្នកម៉ៅការក្តី ដៃគូឯកជនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះសមិទ្ធកម្មនៃការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងក្នុងខនិងលក្ខខណ្ឌនៃកិច្ចសន្យាភ.រ.ជ.។

**មាត្រា៣៨ .–**

ប្រសិនបើគម្រោងភ.រ.ជ.ត្រូវការឱ្យដៃគូឯកជនធានាសមិទ្ធកម្មការងារប្រតិបត្តិការនៃគម្រោងនោះ ដៃគូឯកជនត្រូវផ្តល់កិច្ចធានានេះ ជូនចំពោះស្ថាប័នសាមី ដើម្បីធានាថាការអនុវត្តការងារប្រតិបត្តិការដោយដៃគូឯកជននឹងប្រព្រឹត្តទៅបានត្រឹមត្រូវតាមប៉ារ៉ាម៉ែត្រ និងបទដ្ឋានយថាប្រភេទផ្សេងៗ ដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ឯកសារសម្រាប់អនុវត្តកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជន និងកិច្ចសន្យាភ.រ.ជ. ត្រូវកំណត់នូវតម្រូវការទម្រង់ តម្លៃ និងសុពលភាពនៃកិច្ចធានាសមិទ្ធកម្មការងារប្រតិបត្តិការ ដែលដៃគូឯកជននឹងត្រូវផ្តល់។

**មាត្រា៣៩ .–**

ការងារគ្រប់គ្រង ធ្វើប្រតិបត្តិការ និងថែទាំទ្រព្យសម្បត្តិគម្រោងជាលក្ខណៈពាណិជ្ជកម្មស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមខនិងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ. អាចអនុវត្តដោយដៃគូឯកជនដោយផ្ទាល់ឬតាមរយៈអ្នកម៉ៅការទទួលការងារគ្រប់គ្រងជំនួស។ ក្នុងករណីមានអ្នកម៉ៅការទទួលការងារគ្រប់គ្រងជំនួស ដៃគូឯកជននៅតែត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះសមិទ្ធកម្មនៃការបំពេញកាតព្វកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹងការងារគ្រប់គ្រងធ្វើប្រតិបត្តិការនិងថែទាំទ្រព្យសម្បត្តិគម្រោង ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

ក្នុងអំឡុងពេលអនុវត្តការងារគ្រប់គ្រង ធ្វើប្រតិបត្តិការ និងថែទាំទ្រព្យសម្បត្តិគម្រោង ដៃគូឯកជនត្រូវបំពេញកាតព្វកិច្ចមានជាអាទិ៍៖

១- អនុវត្តសិទ្ធិធ្វើអាជីវកម្មលើទ្រព្យសម្បត្តិគម្រោង ដើម្បីផ្តល់សេវាកម្មដល់អ្នកប្រើប្រាស់ទ្រព្យសម្បត្តិគម្រោងស្របច្បាប់ឱ្យបានស្មើភាពគ្នានិងមិនត្រូវរើសអើងឬបដិសេធការផ្តល់សេវាកម្មដល់អ្នកប្រើប្រាស់ណាដែលបានយល់ព្រមបង់ថ្លៃប្រើប្រាស់ទ្រព្យសម្បត្តិគម្រោង តាមតម្លៃដែលបានផ្សព្វផ្សាយជាសាធារណៈឡើយ។

២- ធានាថាទ្រព្យសម្បត្តិគម្រោងអាចប្រតិបត្តិការបាននិងអាចទទួលការប្រើប្រាស់បានតាមបទដ្ឋានបច្ចេកទេសនិងបទដ្ឋានយថាប្រភេទ ដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

៣- ធ្វើការផ្គត់ផ្គង់ផលិតផលនិង/ឬសេវាកម្មទៅតាមបរិមាណ គុណភាព និងរយៈពេលដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

៤- កាតព្វកិច្ចផ្សេងទៀតដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

**មាត្រា៤០ .-**

ស្ថាប័នសាមីត្រូវទទួលខុសត្រូវចំពោះការងារគ្រប់គ្រង តាមដាន និងរៀបចំរបាយការណ៍វឌ្ឍនភាពគម្រោង របាយការណ៍ក្រោយបញ្ចប់គម្រោង និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀត ស្របតាមកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ. ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំជារបាយការណ៍រួមជូនរាជរដ្ឋាភិបាល ដើម្បីធានាថាការអនុវត្តរបស់គូភាគី អនុលោមតាមខនិងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ក្នុងការអនុវត្តការទទួលខុសត្រូវនេះ ស្ថាប័នសាមីអាចរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងគម្រោង ដែលអាចមានការគាំទ្រពីស្ថាប័នសាធារណៈពាក់ព័ន្ធនិងទីប្រឹក្សាក្នុងផ្នែកពាក់ព័ន្ធ មានជាអាទិ៍ផ្នែកបច្ចេកទេស ច្បាប់ ហិរញ្ញវត្ថុ និងការគ្រប់គ្រងកិច្ចសន្យា។

ដៃគូឯកជនត្រូវទទួលខុសត្រូវចំពោះការរៀបចំរបាយការណ៍ជូនស្ថាប័នសាមីនិងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីស្ថានភាព វឌ្ឍនភាព និងសមិទ្ធកម្មនៃការអនុវត្តគម្រោង រួមបញ្ចូលទាំងសមិទ្ធកម្មហិរញ្ញវត្ថុ តាមតម្រូវការដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

## ជំពូកទី១០
## រយៈពេលនៃកិច្ចសន្យា ការរំលាយកិច្ចសន្យា និងការប្រគល់ទ្រព្យសម្បត្តិគម្រោងជូនរដ្ឋវិញ

**មាត្រា៤១ .-**

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់រយៈពេលនៃកិច្ចសន្យានិងលក្ខខណ្ឌពន្យាររយៈពេលនៃកិច្ចសន្យា។ ការកំណត់រយៈពេលដំបូងបង្អស់នៃកិច្ចសន្យាភ.រ.ជ. ត្រូវផ្អែកទៅលើកត្តាអាយុកាលនៃទ្រព្យសម្បត្តិគម្រោង និងកត្តាពេលវេលា ដែលដៃគូឯកជនត្រូវការដើម្បីរំលស់ថ្លៃដើមនៃការវិនិយោគ។ រយៈពេលដំបូងបង្អស់នៃកិច្ចសន្យាភ.រ.ជ. មិនត្រូវលើសពី៣០(សាមសិប)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចុះកិច្ចសន្យា។ ក្នុងករណីចាំបាច់ ដោយយោងតាមប្រភេទនៃគម្រោងភ.រ.ជ. រាជរដ្ឋាភិបាលអាចកំណត់រយៈពេលដំបូងបង្អស់នៃកិច្ចសន្យាលើសពី៣០(សាមសិប)ឆ្នាំ។

**មាត្រា៤២ .-**

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់ករណីដែលអាចរំលាយកិច្ចសន្យាមុនពេលកំណត់ មានជាអាទិ៍ក្នុងករណីភាគីណាមួយមិនបានបំពេញតាមកាតព្វកិច្ចរបស់ខ្លួន ករណីប្រធានសក្តិនិង/ឬករណីដែលរាជរដ្ឋាភិបាលរំលាយកិច្ចសន្យាមុនពេលកំណត់។

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់សិទ្ធិនិងកាតព្វកិច្ចរបស់គូភាគីដែលត្រូវបំពេញ យន្តការ និងរូបមន្តទូទាត់សំណងសម្រាប់ការរំលាយកិច្ចសន្យាមុនពេលកំណត់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៤៣ .-**

ក្នុងករណីដៃគូឯកជនមានកាតព្វកិច្ចប្រគល់ទ្រព្យសម្បត្តិគម្រោងជូនរដ្ឋវិញ កិច្ចសន្យាភ.រ.ជ. ត្រូវបញ្ជាក់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការប្រគល់ទទួលទ្រព្យសម្បត្តិគម្រោងនោះ។ នៅពេលប្រគល់ទ្រព្យសម្បត្តិគម្រោងជូនរដ្ឋវិញ ដៃគូឯកជនត្រូវធានាថាទ្រព្យសម្បត្តិគម្រោងនោះមានលក្ខណៈត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

ការប្រគល់ទទួលទ្រព្យសម្បត្តិគម្រោង ត្រូវអនុវត្តតាមគោលការណ៍ណែនាំសម្រាប់គ្រប់គ្រងកិច្ចសន្យា ដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

# ជំពូកទី១១
# ការដោះស្រាយវិវាទ

**មាត្រា៤៤ .-**

វិវាទទាំងឡាយណាដែលកើតឡើងរវាងស្ថាប័នសាមីនិងដៃគូឯកជន ពាក់ព័ន្ធនឹងកិច្ចសន្យាភ.រ.ជ.ត្រូវដោះស្រាយទៅតាមយន្តការដោះស្រាយវិវាទដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

**មាត្រា៤៥ .-**

ក្នុងករណីកិច្ចសន្យាភ.រ.ជ.ឬកិច្ចព្រមព្រៀងសម្បទានមិនមានចែងពីយន្តការដោះស្រាយវិវាទ វិវាទដែលកើតឡើងរវាងស្ថាប័នសាមីនិងដៃគូឯកជន ពាក់ព័ន្ធនឹងកិច្ចសន្យាភ.រ.ជ. ឬកិច្ចព្រមព្រៀងសម្បទាន ត្រូវដោះស្រាយតាមរយៈការពិគ្រោះគ្នារវាងស្ថាប័នសាមីនិងដៃគូឯកជន ក្រោមការសម្រុះសម្រួលដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែករណីទាក់ទងនឹងវិវាទដីធ្លី។

ក្នុងរយៈពេល២(ពីរ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរដំបូងពីភាគីណាមួយដែលស្នើសុំធ្វើការសម្រុះសម្រួលគ្នា ប្រសិនបើគូភាគីមិនអាចដោះស្រាយវិវាទតាមការសម្រុះសម្រួលគ្នាទេ គូភាគីអាចព្រមព្រៀងលើកយកវិវាទនោះទៅដោះស្រាយនៅមជ្ឈត្តការពាណិជ្ជកម្មកម្ពុជាឬមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិណាមួយ។ ក្នុងករណីដែលគូភាគីមិនព្រមដោះស្រាយតាមរយៈមជ្ឈត្តការពាណិជ្ជកម្មកម្ពុជាឬមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ ភាគីណាមួយអាចប្ដឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី១២
# ទោសប្បញ្ញត្តិ

**មាត្រា៤៦ .-**

រូបវន្តបុគ្គលដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលរងទណ្ឌកម្មតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

នីតិបុគ្គលក៏ត្រូវទទួលទណ្ឌកម្មស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផងដែរ ក្នុងករណីដែលមន្ត្រី បុគ្គលិក ឬភ្នាក់ងារក្រោមឱវាទរបស់ខ្លួន ធ្វើសកម្មភាពក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារខ្លួនដោយល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

មន្ត្រីរាជការដែលអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនដោយល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលរងទណ្ឌកម្មខាងវិន័យស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌនិងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត។

## ជំពូកទី១៣
## អន្តរប្បញ្ញត្តិ

**មាត្រា៤៧ .-**

ច្បាប់នេះមិនមានអានុភាពអនុវត្តចំពោះគម្រោងអាទិភាពដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលមុនច្បាប់នេះចូលជាធរមាន។ យន្តការនិងនីតិវិធីនៃការរៀបចំអភិវឌ្ឍគម្រោងអាទិភាពនេះត្រូវបន្តរហូតដល់ចប់ ដោយផ្អែកតាមយន្តការនិងនីតិវិធីដែលបានអនុវត្តនៅមុនពេលច្បាប់នេះចូលជាធរមាន។

ក្រៅតែពីបទប្បញ្ញត្តិទាក់ទងនឹងការដោះស្រាយវិវាទដូចមានចែងក្នុងជំពូកទី១១នៃច្បាប់នេះ បទប្បញ្ញត្តិដទៃទៀតនៃច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជនមិនមានអានុភាពអនុវត្តចំពោះកិច្ចព្រមព្រៀងសម្បទាន ឬកិច្ចសន្យាដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកិច្ចសន្យាភ.រ.ឯ. ដែលបានចុះហត្ថលេខាមុនច្បាប់នេះចូលជាធរមាននោះទេ។

## ជំពូកទី១៤
## អវសានប្បញ្ញត្តិ

**មាត្រា៤៨ .-**

ច្បាប់ស្តីពីសម្បទានដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៤៩ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ព្រហស្បតិ៍ ១៤រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០២១

នស/រកម/១១២១/០១៤

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ឧបសម្ព័ន្ធ១

## សន្ទានុក្រម

១- **ការគាំទ្រពីរដ្ឋ** សំដៅដល់ជំនួយហិរញ្ញវត្ថុនិងជំនួយមិនមែនហិរញ្ញវត្ថុដែលរដ្ឋផ្តល់ដើម្បីគាំទ្រការអនុវត្តគម្រោងភ.រ.ជ.។ ការគាំទ្រពីរដ្ឋមានជាអាទិ៍ថវិកាសម្រាប់គម្រោងផ្ទាល់ដែលរាជរដ្ឋាភិបាលបានធានាចំណាយ(ដូចជាការឧបត្ថម្ភធន) កាតព្វកិច្ចបំណុលជាយថាហេតុ (ដូចជាកិច្ចធានាផ្សេងៗ) វិភាគទានជាទ្រព្យសម្បត្តិរដ្ឋនិងជំនួយក្នុងទម្រង់ផ្សេងទៀត។

២- **ការចុះកិច្ចសន្យាផ្ទាល់** សំដៅដល់វិធីសាស្ត្រលទ្ធកម្មជ្រើសរើសដៃគូឯកជនដែលតម្រូវឱ្យចរចាកិច្ចសន្យាផ្ទាល់ជាមួយបេក្ខភាពដៃគូឯកជន ដើម្បីអនុវត្តគម្រោងភ.រ.ជ.។

៣- **ការបំពេញផលហិរញ្ញវត្ថុ** សំដៅដល់ការគាំទ្រពីរដ្ឋមួយប្រភេទដែលជាការឧបត្ថម្ភធនដោយផ្ទាល់ដល់ការចំណាយមូលធនក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ. ដើម្បីបង្កើនផលចំណេញផ្នែកហិរញ្ញវត្ថុរបស់គម្រោងនោះចំពោះដៃគូឯកជន។

៤- **ការសិក្សាសមិទ្ធិលទ្ធភាព** សំដៅដល់ការសិក្សាអំពីលទ្ធភាពអនុវត្តកិច្ចលទ្ធកម្មនិងអនុវត្តគម្រោងតាមយន្តការភ.រ.ជ.។ ការសិក្សាសមិទ្ធិលទ្ធភាពត្រូវមានការពិនិត្យលើទិដ្ឋភាពបច្ចេកទេស ច្បាប់ ទីផ្សារ ពាណិជ្ជកម្ម សេដ្ឋកិច្ច ហិរញ្ញវត្ថុ បរិស្ថាន និងសង្គម ព្រមទាំងមានការវិភាគលើជម្រើសប្រភេទគម្រោងភ.រ.ជ. ការវាយតម្លៃហានិភ័យនានា ការបែងចែកការទទួលបន្ទុកលើហានិភ័យរវាងភាគីរដ្ឋនិងដៃគូឯកជន និងការវាយតម្លៃលើតម្រូវការនៃការគាំទ្រពីរដ្ឋ។

៥- **កិច្ចព្រមព្រៀងនវកម្ម** សំដៅដល់កិច្ចព្រមព្រៀងដែលគូភាគីនៃកិច្ចសន្យាភ.រ.ជ. និងក្រុមហ៊ុនមានគោលបំណងពិសេសត្រូវចុះហត្ថលេខាដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្ទេរសិទ្ធិនិងកាតព្វកិច្ចទាំងស្រុងរបស់ដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ជ. ជូនក្រុមហ៊ុនមានគោលបំណងពិសេស ដោយរក្សាខនិងលក្ខខណ្ឌនៃកិច្ចសន្យាភ.រ.ជ. ដដែល។

៦- **កិច្ចព្រមព្រៀងបន្ទាប់បន្សំ** សំដៅដល់កិច្ចព្រមព្រៀងដែលបានធ្វើឡើងរវាងដៃគូឯកជននិងអ្នកម៉ៅការ ដើម្បីអនុវត្តកាតព្វកិច្ចរបស់ដៃគូឯកជន តាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ស្ថាប័នសាមីមិនតម្រូវឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ទាប់បន្សំនោះទេ ប៉ុន្តែត្រូវពិនិត្យនិងផ្តល់យោបល់លើកិច្ចព្រមព្រៀងនោះ ដើម្បីធានាសង្គតិភាពជាមួយនឹងខនិងលក្ខខណ្ឌនៃកិច្ចសន្យាភ.រ.ជ.។

៧- **កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការអនុវត្តគម្រោងភ.រ.ជ.** សំដៅដល់កិច្ចព្រមព្រៀងដែលបានធ្វើឡើងរវាងស្ថាប័នសាធារណៈ ជាភាគីនៃកិច្ចព្រមព្រៀងជាមួយដៃគូឯកជនឯកជនណាមួយ ដើម្បីគាំទ្រដល់ការអនុវត្តគម្រោងភ.រ.ជ. ពាក់ព័ន្ធជាអាទិ៍នឹងការសាងសង់ ហិរញ្ញប្បទាន ប្រតិបត្តិការ និងការថែទាំ។

៨- **កិច្ចព្រមព្រៀងសម្បទាន** សំដៅដល់កិច្ចព្រមព្រៀងស្របតាមច្បាប់ស្តីពីសម្បទាន។

៩- **កិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន** សំដៅដល់កិច្ចព្រមព្រៀងរវាងស្ថាប័នសាមីនិងដៃគូឯកជន ដែលមានចែងនូវខនិងលក្ខខណ្ឌសម្រាប់អនុវត្តគម្រោងភ.រ.ជ.។ ប្រភេទគម្រោងភ.រ.ជ.ទូទៅ សម្រាប់ជាមូលដ្ឋានក្នុងការកំណត់ទម្រង់នៃកិច្ចសន្យាភ.រ.ជ. មានចែងក្នុងឧបសម្ព័ន្ធ២នៃច្បាប់នេះ។

**១០- ក្រុមហ៊ុនមានគោលបំណងពិសេស** សំដៅដល់សហគ្រាសដែលត្រូវបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា ដោយវិនិយោគិន ស្របតាមខនិងលក្ខខណ្ឌនៃកិច្ចសន្យាភ.រ.ជ. ដោយអនុលោមតាមមាត្រា២២នៃច្បាប់នេះ ដើម្បីធ្វើជាដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ជ. ក្នុងការអនុវត្តគម្រោងភ.រ.ជ.។

**១១- គម្រោងផ្តួចផ្តើមដោយរដ្ឋ** សំដៅដល់គម្រោងដែលត្រូវបានស្នើឡើងរៀបចំនិងការពារដោយស្ថាប័នសាមីនិងមានសក្តានុពលអនុវត្តតាមយន្តការភ.រ.ជ.។ ប្រសិនបើគម្រោងនេះត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ស្ថាប័នសាមីនឹងត្រូវចេញសេចក្តីជូនដំណឹងអំពីការអញ្ជើញដាក់សំណើគម្រោង ដើម្បីជ្រើសរើសដៃគូឯកជន ដោយអនុលោមតាមជំពូកទី៦នៃច្បាប់នេះ។

**១២- គម្រោងផ្តួចផ្តើមដោយឯកជន** សំដៅដល់គម្រោងដែលមានសក្តានុពលអនុវត្តតាមយន្តការភ.រ.ជ. ត្រូវបានស្នើឡើងដោយវិស័យឯកជន តាមរយៈស្ថាប័នសាមី។

**១៣- គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ** សំដៅដល់គំនូរប្លង់ ការសាងសង់ ការថែទាំ ឬការធ្វើអាជីវកម្មនៃសំណង់ហេដ្ឋារចនាសម្ព័ន្ធថ្មី ឬការធ្វើទំនើបភាវូបនីយកម្ម ការពង្រីក ការគ្រប់គ្រង ឬការធ្វើអាជីវកម្មនៃសំណង់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។

**១៤- គម្រោងសេវាសាធារណៈ** សំដៅដល់សេវាដែលត្រូវផ្តល់ដោយស្ថាប័នសាធារណៈតាមមុខងារនិងភារកិច្ចជាធរមាន ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ ជូនដល់សាធារណជនជារូបវន្តបុគ្គលឬនីតិបុគ្គល។ សកម្មភាពនេះអាចកាន់កាប់ដោយរដ្ឋខ្លួនឯងឬអាចប្រគល់ឱ្យឯកជនកាន់កាប់ ប៉ុន្តែស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋ។

**១៥- គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន** សំដៅដល់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិង/ឬគម្រោងផ្តល់សេវាសាធារណៈ ដែលអនុវត្តក្រោមក្របខ័ណ្ឌកិច្ចសន្យាភ.រ.ជ. ដោយអនុលោមតាមច្បាប់នេះ។

**១៦- ដៃគូឯកជន** សំដៅដល់បុគ្គលដែលបានចុះកិច្ចសន្យាភ.រ.ជ. ជាមួយស្ថាប័នសាមី។ ក្នុងករណីក្រុមហ៊ុនមានគោលបំណងពិសេស ត្រូវបានបង្កើតឡើងដោយអនុលោមតាមមាត្រា២២នៃច្បាប់នេះ ដៃគូឯកជនសំដៅដល់ក្រុមហ៊ុនមានគោលបំណងពិសេសនេះវិញ។

**១៧- តម្លៃនៃលុយ** សំដៅដល់ផលចំណេញដែលអាចកើតឡើងចំពោះរដ្ឋ ដោយសារការអនុវត្តគម្រោងណាមួយ តាមរយៈយន្តការភ.រ.ជ. ជាជាងតាមរយៈលទ្ធកម្មសាធារណៈ។

ផលចំណេញនេះអាចវាយតម្លៃ តាមរយៈការវិភាគតាមបែបគុណភាពនិង/ឬតាមបែបបរិមាណលើផលប្រយោជន៍និងចំណាយរបស់រដ្ឋ ក្នុងអាយុកាលទាំងស្រុងនៃគម្រោង។ គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃនេះ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

**១៨- ទីប្រឹក្សា** សំដៅដល់ក្រុមហ៊ុនទីប្រឹក្សា ជំនាញការ និង/ឬអ្នកផ្តល់សេវាដែលមានបទពិសោធន៍ ជាអាទិ៍ផ្នែកហិរញ្ញវត្ថុ ច្បាប់ និងបច្ចេកទេស ក្នុងការរៀបចំអភិវឌ្ឍ និងអនុវត្តគម្រោង ភ.រ.ជ.។

**១៩- ទ្រព្យសម្បត្តិគម្រោង** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តឬប្រព័ន្ធដែលនឹងត្រូវសាងសង់និង/ឬប្រតិបត្តិការ ក្រោមក្របខ័ណ្ឌកិច្ចសន្យាភ.រ.ជ. ដើម្បីផ្តល់សេវាសាធារណៈដោយផ្ទាល់ឬដោយប្រយោល។

**២០- បញ្ជីគម្រោងអាទិភាពក្នុងក្របខ័ណ្ឌគម្រោងភ.រ.ជ.** សំដៅដល់បញ្ជីគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលជាគម្រោងស្ថាប័នសាមីបានធ្វើអត្តសញ្ញាណកម្មនិងអាទិភាវូបនីយកម្ម រួចបានជ្រើសរើសដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមមាត្រា១០នៃច្បាប់នេះ។

**២១- ភាពជាដៃគូរវាងរដ្ឋនិងឯកជន** សំដៅដល់កិច្ចព្រមព្រៀងរវាងភាគីរដ្ឋនិងដៃគូឯកជន ដើម្បីធ្វើការជួសជុល ជួសជុល ពង្រីក សាងសង់ ប្រតិបត្តិការនិង/ឬថែទាំលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬទ្រព្យសម្បត្តិគម្រោង ឬដើម្បីផ្តល់សេវាសាធារណៈ ក្នុងអំឡុងពេលកំណត់ណាមួយ។ ក្នុងកិច្ចព្រមព្រៀងនេះ ដៃគូឯកជនត្រូវធ្វើការវិនិយោគ ទទួលបន្ទុកហានិភ័យមួយចំណែកនិងទទួលអត្ថប្រយោជន៍ផ្អែកទៅលើសមិទ្ធកម្ម តាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

**២២- ម្ចាស់សំណើគម្រោងផ្តួចផ្តើមដោយឯកជន** សំដៅដល់បុគ្គលដែលរៀបចំសំណើគម្រោងផ្តួចផ្តើមដោយឯកជន ដោយអនុលោមតាមមាត្រា២៣នៃច្បាប់នេះ។

**២៣- មូលនិធិអភិវឌ្ឍន៍គម្រោង** សំដៅដល់យន្តការគាំទ្រផ្នែកហិរញ្ញវត្ថុ ដែលប្រើប្រាស់ថវិកាជាតិនិងថវិកាពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់ចំណាយលើការសិក្សារៀបចំអភិវឌ្ឍគម្រោង ធ្វើកិច្ចលទ្ធកម្មនិងការងារពាក់ព័ន្ធផ្សេងទៀត ដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

**២៤- វិនិយោគិន** សំដៅដល់បុគ្គលដែលផ្តល់ហិរញ្ញប្បទានជាភាគទុនដល់ដៃគូឯកជន ដើម្បីអនុវត្តកិច្ចសន្យាភ.រ.ជ. ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**២៥- សិទ្ធិចូលអន្តរាគមន៍** សំដៅដល់សិទ្ធិដែលផ្តល់ជូនដល់អ្នកផ្តល់ប្រាក់កម្ចីនិង/ឬរាជរដ្ឋាភិបាល ដើម្បីចូលគ្រប់គ្រងកិច្ចសន្យាភ.រ.ជ. ក្នុងរយៈពេលណាមួយ ក្នុងករណីដែលដៃគូឯកជន ឬក្រុមហ៊ុនមានគោលបំណងពិសេស មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដែលប៉ះពាល់ធ្ងន់ធ្ងរដល់និរន្តរភាពនៃការអនុវត្តគម្រោងភ.រ.ជ.។

**២៦- សិទ្ធិប្រត្យក្ស** សំដៅដល់សិទ្ធិដែលមាននិយមន័យដូចបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

**២៧- ស្ថាប័នសាមី** សំដៅដល់ក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលគ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវចំពោះការអភិវឌ្ឍគម្រោងនិង/ឬដែលដើរតួជាភាគីរដ្ឋក្នុងការចុះកិច្ចសន្យាភ.រ.ជ. ជាមួយនឹងដៃគូឯកជនសម្រាប់ការអនុវត្តគម្រោងភ.រ.ជ.។

**២៨- សំណើគម្រោងផ្តួចផ្តើមដោយឯកជន** សំដៅដល់ការស្នើសុំជាលាយលក្ខណ៍អក្សររបស់ម្ចាស់សំណើគម្រោងផ្តួចផ្តើមដោយឯកជនជូនចំពោះស្ថាប័នសាមី ដើម្បីរៀបចំអភិវឌ្ឍគម្រោងថ្មីជាគម្រោងភ.រ.ជ. ដែលផ្តល់នូវទស្សនាទានថ្មី បច្ចេកវិទ្យាថ្មី ឬនវានុវត្តន៍ ដល់ព្រះរាជាណាចក្រកម្ពុជា។

**២៩- អ្នកម៉ៅការ** សំដៅដល់ក្រុមហ៊ុនម៉ៅការ អ្នកផ្គត់ផ្គង់ ឬអ្នកផ្តល់សេវា ដែលបានជ្រើសរើសដោយដៃគូឯកជន ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចសន្យាភ.រ.ជ.។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ឧបសម្ព័ន្ធ២

## ប្រភេទគម្រោងភ.រ.ជ. ដែលមានការប្រើប្រាស់ជាទូទៅ

**១- សាងសង់ ធ្វើប្រតិបត្តិការ និងផ្ទេរ** : ស្ថាប័នសាមីផ្តល់សិទ្ធិជូនដៃគូឯកជន ដើម្បីរចនាប្លង់ ហិរញ្ញប្បទាន សាងសង់ ធ្វើប្រតិបត្តិការ និងថែទាំទ្រព្យសម្បត្តិគម្រោង ហើយប្រមូលកម្រៃសេវាថ្លៃប្រើប្រាស់ ថ្លៃឈ្នួល និងថ្លៃផ្សេងទៀត ពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឬអ្នកប្រើប្រាស់ សេវារបស់គម្រោង ក្នុងរយៈពេលដូចបានកំណត់ក្នុងកិច្ចសន្យាភ.រ.ជ.។ ក្រោយពីការបញ្ចប់រយៈពេល នៃកិច្ចសន្យា ដៃគូឯកជនត្រូវផ្ទេរសិទ្ធិនិងអត្ថប្រយោជន៍ដែលជាប់ពាក់ព័ន្ធនឹងគម្រោង ព្រមទាំងទ្រព្យសម្បត្តិគម្រោងឱ្យទៅស្ថាប័នសាមីវិញ ដោយអនុលោមតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ប្រភេទគម្រោងភ.រ.ជ. ដែលមានទម្រង់បែបប្រភេទគម្រោង**សាងសង់ ធ្វើប្រតិបត្តិការ និងផ្ទេរ**ដែរ មានជាអាទិ៍៖

- **សាងសង់ ជួល និងផ្ទេរ** : ដៃគូឯកជនត្រូវរចនាប្លង់ ហិរញ្ញប្បទាន និងសាងសង់ទ្រព្យសម្បត្តិគម្រោង ហើយបន្ទាប់មកដាក់ទ្រព្យសម្បត្តិគម្រោងនោះជួលទៅឱ្យស្ថាប័នសាមីវិញ ដោយទទួលបានកម្រៃ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ប្រភេទគម្រោងនេះរក្សាលក្ខខណ្ឌផ្សេងទៀតនៃប្រភេទគម្រោង**សាងសង់ ធ្វើប្រតិបត្តិការ និងផ្ទេរ** នៅដដែល។
- **សាងសង់ ផ្ទេរ និងធ្វើប្រតិបត្តិការ**: ក្រោយពេលបញ្ចប់ការងារសាងសង់ទ្រព្យសម្បត្តិគម្រោង ដៃគូឯកជនត្រូវផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិគម្រោងនោះ ទៅឱ្យស្ថាប័នសាមីជាមុនសិន។ ប្រភេទគម្រោងនេះរក្សាលក្ខខណ្ឌផ្សេងទៀតនៃប្រភេទគម្រោង**សាងសង់ ធ្វើប្រតិបត្តិការ និងផ្ទេរ**នៅដដែល។

**២- សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ ធ្វើប្រតិបត្តិការ និងផ្ទេរ** : ស្ថាប័នសាមីផ្តល់សិទ្ធិជូនដៃគូឯកជន ដើម្បីរចនាប្លង់ ហិរញ្ញប្បទាន សាងសង់ ធ្វើប្រតិបត្តិការ និងថែទាំទ្រព្យសម្បត្តិគម្រោង ហើយប្រមូលកម្រៃសេវា ថ្លៃប្រើប្រាស់ ថ្លៃឈ្នួល និងថ្លៃផ្សេងទៀត ពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ឬអ្នកប្រើប្រាស់សេវារបស់គម្រោង ក្នុងរយៈពេលដូចបានកំណត់ក្នុងកិច្ចសន្យាភ.រ.ជ.។ ប្រភេទគម្រោងសាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ ធ្វើប្រតិបត្តិការ និងផ្ទេរ ខុសពីប្រភេទគម្រោង**សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ ធ្វើប្រតិបត្តិការ និងផ្ទេរ** ត្រង់ដៃគូឯកជនធ្វើជាម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិគម្រោងក្នុងរយៈពេលនៃកិច្ចសន្យា។ ក្រោយពីការបញ្ចប់រយៈពេលនៃកិច្ចសន្យា ដៃគូឯកជនត្រូវផ្ទេរសិទ្ធិនិងអត្ថប្រយោជន៍ដែលជាប់ពាក់ព័ន្ធនឹងគម្រោង ព្រមទាំងទ្រព្យសម្បត្តិគម្រោងទៅឱ្យស្ថាប័នសាមីវិញ ដោយអនុលោមតាមខនិងលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

**៣- សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការ** : ស្ថាប័នសាមីផ្តល់សិទ្ធិជូនដៃគូឯកជន ដើម្បីរចនាប្លង់ ហិរញ្ញប្បទាន សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការលើទ្រព្យសម្បត្តិគម្រោងជាអចិន្ត្រៃយ៍ ឬក្នុងរយៈពេលមិនកំណត់ ស្របតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ដៃគូឯកជនមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិគម្រោងជាលក្ខណៈពាណិជ្ជកម្ម

ហើយមានសិទ្ធិប្រមូលកម្រៃនិងចំណូលផ្សេងទៀត ពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឬអ្នកប្រើប្រាស់សេវារបស់គម្រោង។ ប្រភេទគម្រោងភ.រ.ជ. ដែលមានទម្រង់បែបប្រភេទគម្រោង**សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការ**ដែរ មានជាអាទិ៍៖

- **ស្តារនីតិសម្បទា ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការ**: ប្រភេទគម្រោងនេះមានលក្ខខណ្ឌដូចប្រភេទគម្រោង**សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការ**ដែរ តែដៃគូឯកជនត្រូវទទួលសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិគម្រោងដែលមានស្រាប់ដើម្បីធ្វើការស្តារនីតិសម្បទានៃទ្រព្យសម្បត្តិគម្រោងនោះ។
- **ទំនើបភាវូបនីយកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការ** : ប្រភេទគម្រោងនេះមានលក្ខខណ្ឌដូចប្រភេទគម្រោង**សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការ**ដែរ តែដៃគូឯកជនត្រូវទទួលសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិគម្រោងដែលមានស្រាប់ដើម្បីធ្វើទំនើបភាវូបនីយកម្មលើទ្រព្យសម្បត្តិគម្រោងនោះ។

**៤- កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រង/កិច្ចព្រមព្រៀងស្តីពីប្រតិបត្តិការ និងការថែទាំ** : ដៃគូឯកជនត្រូវផ្តល់សេវាកម្មប្រចាំថ្ងៃ ដែលពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការ និងការថែទាំលើទ្រព្យសម្បត្តិគម្រោងដែលមានស្រាប់ ឬទ្រព្យសម្បត្តិរដ្ឋផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់ស្ថាប័នសាមី ដោយទទួលបានកម្រៃសេវាពីស្ថាប័នសាមីឬភាគីផ្សេងទៀត ស្របតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ជាទូទៅ កិច្ចសន្យាបែបនេះមិនតម្រូវឱ្យដៃគូឯកជនចំណាយមូលធនរបស់ខ្លួនដើម្បីធ្វើការវិនិយោគនិងមិនផ្តល់កម្មសិទ្ធិលើទ្រព្យសម្បត្តិគម្រោង ឬទ្រព្យសម្បត្តិរដ្ឋណាមួយជូនដៃគូឯកជនឡើយ។ ក្នុងករណីដែលគម្រោងតម្រូវឱ្យដៃគូឯកជនចំណាយមូលធនរបស់ខ្លួន ដើម្បីធ្វើការវិនិយោគនោះ ដៃគូឯកជនអាចរំលស់ថ្លៃដើមនៃការវិនិយោគនេះតាមរយៈការទូទាត់ពីស្ថាប័នសាមីឬពីភាគីផ្សេងទៀត តាមខនិងលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

**៥- រចនាប្លង់ សាងសង់ ហិរញ្ញប្បទាន ធ្វើប្រតិបត្តិការ និងថែទាំ** : ស្ថាប័នសាមីផ្តល់សិទ្ធិជូនដៃគូឯកជន ដើម្បីរចនាប្លង់ សាងសង់ ហិរញ្ញប្បទាន ផ្តល់សេវាកម្មប្រតិបត្តិការ និងសេវាកម្មថែទាំ ចំពោះទ្រព្យសម្បត្តិគម្រោង ដោយអនុលោមតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យា ភ.រ.ជ.។ ដៃគូឯកជនមានសិទ្ធិប្រមូលប្រាក់ចំណូល ពីការផ្តល់សេវាកម្មខាងលើ តាមរយៈការទូទាត់ពីស្ថាប័នសាមី ឬភាគីផ្សេងទៀត តាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ក្រោយពីការបញ្ចប់រយៈពេលនៃកិច្ចសន្យា ដៃគូឯកជនត្រូវផ្ទេរទ្រព្យសម្បត្តិគម្រោងទៅឱ្យស្ថាប័នសាមីវិញ។

**៦- រចនាប្លង់ សាងសង់ និងជួល** : ស្ថាប័នសាមីផ្តល់សិទ្ធិជូនដៃគូឯកជនដើម្បីរចនាប្លង់ សាងសង់ និងជួលទ្រព្យសម្បត្តិគម្រោងពីស្ថាប័នសាមី ធ្វើប្រតិបត្តិការ និងសេវាកម្មថែទាំ តាមខនិងលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

**៧- ប្រភេទគម្រោងភ.រ.ជ.ផ្សេងទៀត។**